ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
លេខ : 01 ប្រក.ព

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## លទ្ធផលនៃសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ថ្ងៃសុក្រ ៣កើត ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២២

នៅព្រឹកថ្ងៃសុក្រ ៣កើត ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២២ វេលាម៉ោង៨និង១៥នាទីព្រឹក នៅវិមានសន្តិភាព ទីស្តីការគណៈរដ្ឋមន្ត្រី មានបើកកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិនិត្យនិងពិភាក្សាលើ៖

**១-សេចក្តីព្រាងច្បាប់ស្តីពីការការពាររុក្ខជាតិនិងភូតគាមអនាម័យ។**
**២-បញ្ហាផ្សេងៗ ។**

ក្រោយពីបានស្តាប់របាយការណ៍ សម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីបានធ្វើការពិភាក្សាផ្លាស់ប្តូរយោបល់ និងសម្រេចតាមរបៀបវារៈ ដែលមានលទ្ធផលនិងខ្លឹមសារសង្ខេបដូចខាងក្រោម៖

### ១-សេចក្តីព្រាងច្បាប់ស្តីពីការការពាររុក្ខជាតិនិងភូតគាមអនាម័យ

សេចក្តីព្រាងច្បាប់ស្តីពីការការពាររុក្ខជាតិនិងភូតគាមអនាម័យ គឺជាសមិទ្ធផលថ្មីមួយទៀតក្នុងការអភិវឌ្ឍបទដ្ឋានគតិយុត្តរបស់វិស័យកសិកម្ម ក្នុងក្របខ័ណ្ឌបង្កើនផលិតភាព ពិពិធកម្មកសិកម្ម និងកសិ-ធុរកិច្ច ខណៈដែលព្រះរាជាណាចក្រកម្ពុជាគឺជាប្រទេសសមាជិកអាស៊ាន និងអង្គការពាណិជ្ជកម្មពិភពលោក ព្រមទាំងត្រូវបានទទួលស្គាល់ជារដ្ឋភាគីភ្ជាប់កាតព្វកិច្ចនៃអនុសញ្ញាអន្តរជាតិស្តីពីការការពាររុក្ខជាតិ កាលពីឆ្នាំ១៩៥២ ដែលមានសមាជិកភាគីសរុប១៣៩រដ្ឋ។

សេចក្តីព្រាងច្បាប់នេះត្រូវបានរៀបចំឡើងដោយផ្អែកលើគោលនយោបាយនិងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល និងអនុលោមតាមមូលដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ព្រមទាំងកិច្ចព្រមព្រៀងនិងអនុសញ្ញាក្នុងតំបន់និងអន្តរជាតិស្តីពីការការពាររុក្ខជាតិនិងភូតគាមអនាម័យ និងជាពិសេស យោងតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីឆ្លើយតបទៅនឹងនិន្នាការរីកចម្រើននៃវិស័យកសិកម្ម ក្នុងក្របខ័ណ្ឌសុវត្ថិភាពស្បៀង ការលើកកម្ពស់គុណភាពផលិតផលកសិកម្ម ការបង្កើនការនាំចេញកសិផល និងធានាចីរភាពអភិវឌ្ឍន៍ក្នុងបរិការណ៍សមាហរណកម្មសេដ្ឋកិច្ចពិភពលោកប្រកបដោយការប្រកួតប្រជែង។

សេចក្ដីព្រាងច្បាប់នេះមានគោលបំណងកំណត់អំពីការគ្រប់គ្រងសុខភាពរុក្ខជាតិ ការអនុវត្តវិធានការការពាររុក្ខជាតិនិងវិធានការភូតគាមអនាម័យ ការការពារធនធានរុក្ខជាតិគ្រប់ប្រភេទ ការទប់ស្កាត់ការបង្ក ការរាលដាលឆ្លង និងការរាតត្បាតពីសំណាក់សមាសភាពចង្រៃ ការលើកកម្ពស់ផលិតភាពកសិកម្ម សន្តិសុខស្បៀង អនាម័យ គុណភាព និងសុវត្ថិភាពផលិតផលកសិកម្ម ព្រមទាំងសន្តិសុខភូតគាមអនាម័យនៃរុក្ខជាតិ ផលិតផលរុក្ខជាតិ និងទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ ការសម្រួលការធ្វើពាណិជ្ជកម្ម ការនាំចេញ ការនាំចូល ការដឹកជញ្ជូនឆ្លងកាត់នូវផលិតផលដំណាំ រុក្ខជាតិ និងផលិតផលរុក្ខជាតិ ព្រមទាំងការរួមចំណែកការអភិវឌ្ឍសេដ្ឋកិច្ចសង្គមជាតិនិងការលើកកម្ពស់សុខុមាលភាពនិងសុខភាពសាធារណៈ ប្រកបដោយនិរន្តរភាពធនធានធម្មជាតិ និងប្រព័ន្ធអេកូឡូស៊ី ដើម្បីធានាការគ្រប់គ្រងការពាររុក្ខជាតិ និងភូតគាមអនាម័យនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

បន្ថែមពីលើនេះ សេចក្ដីព្រាងច្បាប់ខាងលើនឹងរួមចំណែកផ្ដល់នូវសារៈប្រយោជន៍ក្នុងការអភិវឌ្ឍវិស័យកសិកម្ម ដូចជា ការការពារផលប្រយោជន៍របស់ប្រជាកសិករតាមរយៈការគ្រប់គ្រងការពាររុក្ខជាតិនិងអនុវត្តវិធានការភូតគាមអនាម័យ, ការគាំទ្រគោលនយោបាយនិងយុទ្ធសាស្ត្រជំរុញផលិតកម្មកសិកម្ម ពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម, ការផ្ដល់នូវឧបករណ៍បទដ្ឋានគតិយុត្តដ៏រឹងមាំ និងយន្តការគ្រប់ជ្រុងជ្រោយក្នុងការអនុវត្តវិធានការការពាររុក្ខជាតិនិងភូតគាមអនាម័យ, ការផ្ដល់នូវវិធានការច្បាស់លាស់ក្នុងការការពារធនធានរុក្ខជាតិ គ្រប់គ្រងសុខភាពរុក្ខជាតិ លើកកម្ពស់ផលិតភាព គុណភាព និងសុវត្ថិភាពផលិផលកសិកម្មប្រកបដោយភាតរបរិស្ថាននិងនិរន្តរភាព, ការរក្សាអធិបតេយ្យភាពនិងសន្តិសុខភូតគាមអនាម័យ, ការបំពេញបាននូវលក្ខខណ្ឌតម្រូវនិងស្ដង់ដារភូតគាមអនាម័យអន្តរជាតិ និងការផ្ដល់ជំនឿទុកចិត្តជាមួយប្រទេសដៃគូពាណិជ្ជកម្ម និងកម្លាំងពលកម្មពេញលេញ ក្នុងការចរចាបើកទីផ្សារនាំចេញកសិផលកម្ពុជាជាមួយបណ្ដាប្រទេសដែលមានទីផ្សារធំៗក្នុងពិភពលោក។

សេចក្ដីព្រាងច្បាប់ស្ដីពីការការពាររុក្ខជាតិនិងភូតគាមអនាម័យ ត្រូវបានរៀបចំឡើងដោយមាន១៥ជំពូក និង១១៣មាត្រា ហើយត្រូវបានសម្រេចឯកភាពដោយអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី។

## ២-បញ្ហាផ្សេងៗ

សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានមានប្រសាសន៍ថា៖

- ក្រសួងសុខាភិបាល ក្រសួងស្ថាប័នពាក់ព័ន្ធ គ្រប់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ត្រូវខិតខំបន្តពន្លឿនការចាក់វ៉ាក់សាំងដូសជំរុញជាដូសទី៣ជូនប្រជាពលរដ្ឋឱ្យបានគ្រប់ៗគ្នា ព្រមទាំងអំពាវនាវដល់ប្រជាពលរដ្ឋដែលមិនទាន់បានចាក់វ៉ាក់សាំងនៅឡើយ ត្រូវមកទទួលការចាក់វ៉ាក់សាំងឱ្យបានឆាប់រហ័សនៅតាមទីតាំងដែលបានរៀបចំ ដើម្បីបង្កើនភាពស៊ាំនៅក្នុងសហគមន៍ ដែលឆ្លើយតបនឹងការបើកដំណើរការសេដ្ឋកិច្ចសង្គមឡើងវិញក្នុងគន្លងប្រក្រតីភាពថ្មី

- រាជរដ្ឋាភិបាលកម្ពុជា បន្តជំរុញយុទ្ធនាការចាក់វ៉ាក់សាំងដូសជំរុញទី៤ ជូនមន្ត្រីរាជការកងកម្លាំងប្រដាប់អាវុធ និងប្រជាពលរដ្ឋនៅរាជធានីភ្នំពេញ និងតាមបណ្ដាខេត្តនានានៅពេលណាដែលទទួលបាននូវបរិក្ខារប្រព័ន្ធត្រជាក់សម្រាប់រក្សាទុកវ៉ាក់សាំងបានត្រឹមត្រូវ

- រាជរដ្ឋាភិបាលកម្ពុជា ខិតខំបញ្ចៀសមិនឱ្យមានករណីប្រជាជនស្លាប់ជាថ្មីទៀតដោយសារជំងឺកូវីដ-១៩ ដោយធានាថាព្រះរាជាណាចក្រកម្ពុជានឹងមិនខ្វះវ៉ាក់សាំងសម្រាប់ចាក់ជូនប្រជាពលរដ្ឋនៅពេលដែលបញ្ហាជំងឺកូវីដ-១៩ មិនទាន់ចប់នៅឡើយ

- រាជរដ្ឋាភិបាលថ្លែងកោតសរសើរចំពោះវឌ្ឍនភាពនៃការបើកសេដ្ឋកិច្ចឡើងវិញរបស់ព្រះរាជាណាចក្រកម្ពុជា ដែលបានធ្វើឱ្យចំណូលពន្ធដារមានការកើនឡើង ហើយសកម្មភាពសេដ្ឋកិច្ចមានដំណើរការល្អឡើងវិញ ដែលនេះជាចំណុចល្អសម្រាប់សេដ្ឋកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជាក្នុងការធានាចំណាយកន្លងមក

- សន្តិភាព គឺពិតជាមានតម្លៃខ្លាំងណាស់មិនអាចកាត់ថ្លៃបាន ដែលបានជួយឱ្យព្រះរាជាណាចក្រកម្ពុជាមានការអភិវឌ្ឍលើគ្រប់វិស័យ ជាពិសេស ធ្វើឱ្យប្រជាជនគ្រប់ៗរូបរស់នៅដោយសុខសន្តិភាព សុវត្ថិភាព មានសុខុមាលភាពពេញលេញ ជីវភាពល្អប្រសើរ មានសិទ្ធិសេរីភាព និងអាចធ្វើដំណើរ ឬទៅកម្សាន្តនៅតាមទីកន្លែងនានា ព្រមទាំងប្រារព្ធពិធីសាសនាផ្សេងៗ ប្រកបដោយសុខដុមនីយកម្ម

- រាជរដ្ឋាភិបាលកម្ពុជានឹងទទួលស្វាគមន៍នាយករដ្ឋមន្ត្រីម៉ាឡេស៊ី ដែលគ្រោងនឹងមកបំពេញទស្សនកិច្ចផ្លូវការនៅព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២២ នេះ

- ព្រះរាជាណាចក្រកម្ពុជាក្នុងនាមជាប្រធានប្ដូរវេនអាស៊ាន គាំទ្រនិងលើកទឹកចិត្តដល់បណ្ដាប្រទេសជាសមាជិកអាស៊ានដើម្បីខិតខំជំរុញការអនុវត្តទស្សនាទានអាស៊ានស្ដីពីឥណ្ឌូប៉ាស៊ីហ្វិកអាចចេញជាសកម្មភាពជាក់ស្ដែង ព្រមទាំងបន្តខិតខំប្រឹងប្រែងទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ជំរុញការបើកសេដ្ឋកិច្ចឡើងវិញ និងប្រកាន់ខ្ជាប់គោលការណ៍កុងសង់ស៊ីសរបស់អាស៊ាន

- រាជរដ្ឋាភិបាលកម្ពុជាថ្លែងអំណរគុណដល់បណ្ដាប្រទេសនានាដែលតែងតែគាំទ្រព្រះរាជាណាចក្រកម្ពុជាចំពោះការបំពេញតួនាទីស្នូលក្នុងក្របខ័ណ្ឌអាស៊ាន ព្រមទាំងទទួលស្គាល់នូវអត្ថិភាពដ៏សំខាន់របស់ព្រះរាជាណាចក្រកម្ពុជាក្នុងសហគមន៍អាស៊ាន

- ថវិកាដែលទទួលបានពីការលក់សៀវភៅរឿង "គូព្រេង មិនព្រាត់" និងថវិកាចំនួន១លានដុល្លារអាម៉េរិកទទួលបានពីពានរង្វាន់ "សន្តិភាពស៊ិនហាក់ ឆ្នាំ២០២២" របស់ សម្ដេចតេជោនាយករដ្ឋមន្ត្រី នឹងត្រូវប្រើប្រាស់សម្រាប់ការបន្តសាងសង់លំនៅដ្ឋានជូនអតីតយុទ្ធជនកម្ពុជា។

អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានបិទសម័យប្រជុំនៅវេលាម៉ោង១០និង១៨នាទី។

ថ្ងៃសុក្រ ៣កើត ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២២